D54/V/6

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី
ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម
ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៧)

| | | |
|---|---|---|
| ចំពោះមុខ: | ចៅក្រម ប្រាក់ គឹមសាន | ប្រធាន |
| | ចៅក្រម Rowan DOWNING | |
| | ចៅក្រម ន៉ី ថុល | |
| | ចៅក្រម Katinka LAHUIS | |
| | ចៅក្រម ហួត វុទ្ធី | |
| កាលបរិច្ឆេទ: | ២២ តុលា ២០០៨ | |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 22 / OCT / 2008
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

សាធារណៈ

## សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ចំពោះការចាត់តាំងអ្នកជំនាញ

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**

នួន ជា

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke STUDZINSKY
យុង ផានិត
គឹម ម៉េងឃី
Martine JACQUIN

**សហមេធាវីការពារក្តី**

សុន អរុណ
Michiel PESTMAN
Victor KOPPE

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 22 / OCT / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER * CHAMBRE PRELIMINAIRE * ECCC * E.C.T.C.

00233629

D54/V/6

០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៧)

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ត.ក" ទទួលបាន "បណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាបដិសេធសំណើសុំចាត់តាំងអ្នកជំនាញ" ដែលសហមេធាវីការពារក្តីរបស់លោក **នួន ជា** ("ជនត្រូវចោទ") បានដាក់នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៨ ("បណ្តឹងឧទ្ធរណ៍")។

## **ជំពូក ១ - សាវតា**

១. នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ សហមេធាវីការពារក្តីរបស់ជនត្រូវចោទ បានដាក់ "សំណើសុំចាត់តាំងអ្នកជំនាញ" នៅចំពោះមុខចៅក្រមស៊ើបអង្កេត ("សំណើសុំ")[១]។ តាមរយៈសំណើសុំនេះ សហមេធាវីការពារក្តីស្នើសុំសហចៅក្រមស៊ើបអង្កេតឱ្យចាត់តាំងអ្នកជំនាញ ដើម្បីវាយតម្លៃសម្បទារបស់ជនត្រូវចោទ ក្នុងការចូលរួមក្នុងការជំនុំជម្រះ ពិសេសជាងនេះទៀតគឺសម្បទារបស់គាត់ ក្នុងការចូលរួមដោយប្រសិទ្ធភាពក្នុងការការពារខ្លួនគាត់។[២] សហព្រះរាជអាជ្ញា បានដាក់សេចក្តីសន្និដ្ឋានតប នៅថ្ងៃទី៩ ខែមករា ឆ្នាំ២០០៨[៣] ហើយមេធាវីការពារក្តីបានដាក់សារណាតបនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨[៤]។

២. នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៨ សហមេធាវីការពារក្តីជាតិរបស់ជនត្រូវចោទ បានបញ្ជូនលិខិតមួយច្បាប់ ជូនសហចៅក្រមស៊ើបអង្កេត ដោយក្នុងនោះបានស្នើសុំ "ការបញ្ជាក់ថា ដល់ពេលណាទើបការិយាល័យរបស់សហចៅក្រមស៊ើបអង្កេត ចង់សម្រេចដោះស្រាយលើបណ្តឹងឧទ្ធរណ៍នេះ"[៥]។

៣. នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានឆ្លើយតបដូចខាងក្រោម

---

[១] ពាក្យសុំចាត់តាំងអ្នកជំនាញ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ D54 ទំព័រទី ១។

[២] ពាក្យសុំ វាក្យខណ្ឌទី ៦។

[៣] សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាស្តីពីពាក្យសុំរបស់លោក នួន ជា ស្នើសុំការចាត់តាំងអ្នកជំនាញ និងការផ្អាកបណ្តោះអាសន្ន ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០០៨ D54/I ទំព័រទី ៦។

[៤] សារណាតបទៅនឹងសេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាស្តីពីពាក្យសុំរបស់លោក នួន ជា ស្នើសុំការចាត់តាំងអ្នកជំនាញ និងការផ្អាកបណ្តោះអាសន្ន ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ D54/II ទំព័រទី ៦។

[៥] លិខិតរបស់លោក សុន អរុណ ផ្ញើរជូនការិយាល័យសហចៅក្រមអង្កេត ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៨ D54/III។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

("លិខិតចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៨")៖

"ជាបឋម យើងសូមបញ្ជាក់ជូនលោកថា យើង មិនបានភ្លេចអំពីសំណើរបស់លោកទេ ប៉ុន្តែ បើផ្អែកតាមលិខិតរបស់លោកថ្មីៗនេះ យើង អាចបញ្ជាក់បានដូចខាងក្រោម៖

"១. បញ្ហាភាពសមស្របរបស់កូនក្តីលោកសម្រាប់ការកាត់ទោសនោះ មិនអាចលើកឡើង នៅដំណាក់កាលនេះទេ ដោយសារថា ការបញ្ជូនកូនក្តីរបស់លោកទៅកាត់ទោស មិនមែនជាបញ្ហាដែល ត្រូវលើកឡើងនៅពេលនេះនោះទេ។

២. ដូចគ្នាដែរ ភាពសមស្របនៃកូនក្តីលោក ក្នុងការចូលរួមក្នុងកិច្ចការស៊ើបអង្កេតវិញ ក៏មិនអាចលើកឡើងនាពេលនេះដែរ ដោយសារនៅពេលនេះ កូនក្តីរបស់លោក បានបដិសេធមិនឱ្យសួរ ចម្លើយទេ។

៣. លើសពីនេះ ការលើកឡើងអំពីករណីដែលថាកូនក្តីរបស់លោកចាំបាច់ត្រូវមានសុខភាព រឹងមាំ ដើម្បីអាចពិភាក្សាផ្តល់ព័ត៌មានជូនមេធាវី មិនអាចជាអំណះអំណាងដើម្បីឱ្យមានការធ្វើ កោលសល្យវិច័យនោះទេ។ លោកមិនបានលើកឡើងនូវអំណះអំណាងណាមួយទាល់តែសោះ ដែល អាចចង្អុលបង្ហាញថា បញ្ហានេះកំពុងតែកើតមានឡើង។ យើងកត់សម្គាល់ថា កូនក្តីរបស់លោក ត្រូវបានពិនិត្យសុខភាពយ៉ាងទៀងទាត់ (នៅពេលថ្មីៗបំផុតគឺកាលពីសប្តាហ៍មុន) ហើយមិនមាន វេជ្ជបណ្ឌិតណាម្នាក់ បានលើកឡើងបញ្ហាណាមួយគួរឱ្យកត់សម្គាល់នោះទេ។"[៦]

ដូចដែលបានជម្រាបខាងលើ យើងនឹងសម្រេចអំពីសំណើរបស់លោកក្នុងពេលឆាប់ៗសម ស្របតាមបទប្បញ្ញត្តិនៃវិធាន ៣១ វិធាន ៣២ និងវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង។

៤. នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៨ សហមេធាវីការពារក្តី បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹង ឧទ្ធរណ៍ប្រឆាំងចំពោះ "លិខិតរបស់សហចៅក្រមស៊ើបអង្កេត ដែលឆ្លើយតបទៅនឹងសំណើសុំ ចាត់តាំងអ្នកជំនាញសម្រាប់លោក **នួន ជា**"[៧]។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៨ សហមេធាវី ការពារក្តីបានដាក់សារណាបណ្តឹងឧទ្ធរណ៍គឺ "សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកា បដិសេធសំណើសុំចាត់តាំងអ្នកជំនាញ"[៨]។

---

[៦] លិខិតរបស់សហចៅក្រម Marcel Lemonde ផ្ញើរជូន លោក សុន អរុណ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៨ D54/IV។

[៧] សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៨ D54/V និងសៀវភៅចុះបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៨ D54/V។

[៨] បណ្តឹងឧទ្ធរណ៍ចំពោះដីកាបដិសេធពាក្យសុំចាត់តាំងអ្នកជំនាញ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៨ D54/V/1 ("បណ្តឹងឧទ្ធរណ៍")។

00233631



៥. នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានដាក់ "សេចក្តីសន្និដ្ឋានតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់លោក **នួន ជា** ចំពោះសំណើសុំចាត់តាំងអ្នកជំនាញ ដើម្បីវាយតម្លៃសម្បទារបស់គាត់ក្នុងចូលរួមក្នុងការជំនុំជម្រះ"[៩]

៦. មេធាវីដើមបណ្តឹងរដ្ឋប្បវេណី មិនបានដាក់សារណាតបឡើយ។

៧. នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានសម្រេចថា បណ្តឹងឧទ្ធរណ៍នេះ នឹងយកមកធ្វើការសម្រេច ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ ហើយអនុញ្ញាតឱ្យសហមេធាវីការពារក្តីលោក **នួន ជា** ដាក់សារណាតបទៅនឹងសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា ក្នុងរយៈពេលប្រាំ(៥)ថ្ងៃ[១០]។ សហមេធាវីការពារក្តីមិនបានដាក់សារណាតបណាមួយឡើយ។

## ជំពូក ២ - ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

៨. អង្គបុរេជំនុំជម្រះសង្កេតឃើញថា លិខិតចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៨ ត្រូវបានជូនដំណឹងចំថ្ងៃសុក្រ នៅវេលាម៉ោង ៥:២២ នាទី រសៀល។ ដោយសារការជូនដំណឹងនេះ បានធ្វើឡើងបន្ទាប់ពីម៉ោង ៤ រសៀល សេចក្តីជូនដំណឹងចាត់ទុកថា បានជូនដំណឹងនៅថ្ងៃចន្ទ នៃសប្តាហ៍ក្រោយ គឺថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៨។ សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានដាក់ក្នុងរយៈពេលដប់(១០)ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីលិខិតចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៨ ហេតុដូច្នេះ សេចក្តីជូនដំណឹងនេះ បានធ្វើឡើងទាន់ពេលវេលា។

---

[៩] សេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ចំពោះការចាត់តាំងអ្នកជំនាញ ដើម្បីវាយតម្លៃសម្បទាចូលរួមក្នុងការជំនុំជម្រះ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ D54/V/2។

[១០] សេចក្តីសម្រេចលើសំណើសុំឱ្យធ្វើការសម្រេចបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ដែលប្តឹងចំពោះការចាត់តាំងអ្នកជំនាញ ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ តែប៉ុណ្ណោះ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៨ D54/V/4។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

៩. សហមេធាវីការពារក្តីសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន ដោយសារ "លិខិតរបស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៨" បានបង្ហាញនូវការបដិសេធដ៏ច្បាស់លាស់ចំពោះសំណើសុំ តាមវិធាន ៣១(១០) នៃវិធានផ្ទៃក្នុង"[១១]។ ម្យ៉ាងវិញទៀត សហមេធាវីការពារក្តីបានសន្និដ្ឋានថា "អនុលោមតាមមាត្រា ១៧០ នៃក.ន.ព.ក (ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា) [អង្គបុរេជំនុំជម្រះ] មានសមត្ថកិច្ចសម្រេចលើសំណើសុំ តាំងពីដំណាក់កាលដំបូង"[១២]។ ក្នុងករណីនេះ សហមេធាវីអះអាងថា វិធាន ៣១(១០) នៃវិធានផ្ទៃក្នុង គួរប្រកាសថា គ្មានសុពលភាព ដោយសារវិធាននេះផ្ទុយនឹងមាត្រា ១៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្រមនេះចែងយ៉ាងច្បាស់ អំពីរយៈពេលកំណត់ចំនួនសាមសិប (៣០)ថ្ងៃ សម្រាប់ការចេញសេចក្តីសម្រេចលើសំណើសុំចាត់តាំងអ្នកជំនាញ។

១០. សហព្រះរាជអាជ្ញា មិនបានធ្វើសេចក្តីសន្និដ្ឋានណាមួយ ចំពោះភាពដែលអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍។

១១. វិធាន ៣១(១០) នៃវិធានផ្ទៃក្នុងចែងថា:

> "សហព្រះរាជអាជ្ញា ជនត្រូវចោទ ឬជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ឬមេធាវីរបស់ពួកគេអាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះចាត់តាំងអ្នកជំនាញថ្មីបន្ថែមទៀត ដើម្បីធ្វើការត្រួតពិនិត្យថ្មី ឬត្រួតពិនិត្យឡើងវិញលើបញ្ហាណាមួយដែលធ្វើរួចហើយ និងមានក្នុងរបាយការណ៍របស់អ្នកជំនាញមុន។ សំណើនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានបញ្ជាក់មូលហេតុ។ សំណើនេះត្រូវ<u>សម្រេច</u>ដោយសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ<u>ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងមុនពេលបញ្ចប់ការស៊ើបសួរ</u> ឬកិច្ចដំណើរការនីតិវិធី។ <u>នៅពេលដែលសហចៅក្រមស៊ើបអង្កេតបដិសេធមិនព្រមធ្វើតាមសំណើ ដីកាបដិសេធនេះអាចត្រូវប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ</u>"។ (គូសបញ្ជាក់បន្ថែម)

---

[១១] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ១១។

[១២] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ១១។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C.

១២. វិធាន ៧៤(៣)(ឃ) នៃវិធានផ្ទៃក្នុងចែងទៀតថា ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត "ដែលបដិសេធសំណើសុំរបាយការណ៍របស់អ្នកជំនាញ ដែលអនុញ្ញាតក្រោម[វិធានផ្ទៃក្នុង]នេះ"។ (គូសបញ្ជាក់បន្ថែម)

១៣. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានសម្រេចថា សម្បទារបស់ជនត្រូវចោទ (...) ក្នុងការណែនាំដល់មេធាវី មិនអាចផ្តល់យុត្តិកម្មក្នុងការធ្វើកោសល្យវិច័យឡើយ" ដោយសារសហមេធាវីការពារក្តី "មិនបានចង្អុលបង្ហាញចំពោះផ្នែកណាមួយដែលយ៉ាងហោចណាស់ ជាបញ្ហាចំពោះសុខភាព"។

១៤. ប៉ុន្តែ សំណើសុំនេះ មិនកម្រិតត្រឹមបញ្ហាសមត្ថភាពរបស់ជនត្រូវចោទ ក្នុងការណែនាំដល់មេធាវីឡើយ។ ជាការពិត សំណើសុំនេះមានលក្ខណៈទូលាយ ដោយក្តោបរួមទាំងសមត្ថភាពរបស់ជនត្រូវចោទ ក្នុងការ "ចូលរួមដោយប្រសិទ្ធិភាព" នៅក្នុងដំណើរការក្តីព្រហ្មទណ្ឌ"[១៣] និង ជាពិសេសនោះគឺ "សមត្ថភាពក្នុងការសារភាពទោស ផ្តល់សក្ខីកម្ម ណែនាំដល់មេធាវី យល់ដឹងអំពីលក្ខណៈនៃបទចោទ យល់ដឹងអំពីព័ត៌មានពិស្តារនៃភស្តុតាង យល់ដឹងអំពីដំណាក់ការនីតិវិធី និងផលវិបាកនៃដំណើរការក្តី"[១៤]។

១៥. អង្គបុរេជំនុំជម្រះសង្កេតឃើញថា ដោយគ្រាន់តែអះអាងថា"បញ្ហាសម្បទារបស់កូនក្តីក្នុងការចូលរួមក្នុងដំណើរការស៊ើបអង្កេត មិនជាបញ្ហាពាក់ព័ន្ធឡើយ ដោយសារនៅពេលនេះ កូនក្តីលោកបដិសេធមិនឆ្លើយ" សហចៅក្រមស៊ើបអង្កេតស្នើឡើងថា ការពាក់ព័ន្ធរបស់ជនត្រូវចោទ ក្នុងដំណាក់ការស៊ើបអង្កេត គឺកម្រិតត្រឹមការចូលរួមរបស់គាត់នៅក្នុងការសួរចម្លើយ។ ចំនុចសំខាន់នោះ សហចៅក្រមស៊ើបអង្កេតបានសម្រេចថា ត្រឹមតែសមត្ថភាពរបស់ជនត្រូវចោទក្នុងការពន្យល់ណែនាំដល់មេធាវីប៉ុណ្ណោះ ដែលជាបញ្ហា ដោយសារគាត់មិនព្រមចូលរួមនៅក្នុងការសួរចម្លើយ។

---

[១៣] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ១៥។

[១៤] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ១៦។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

១៦. ដោយសារបញ្ហានេះ ជនត្រូវចោទ ទទួលការបដិសេធចំពោះលទ្ធភាពនៃការធ្វើកោសល្យវិច័យដោយអ្នកជំនាញ ចំពោះសម្បទាស្មារតីរបស់គាត់ ក្នុងការចូលរួមក្នុងការការពារខ្លួនក្នុងដំណាក់ការស៊ើបអង្កេត។ សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បង្ហាញជាការបដិសេធទាំងស្រុងតែម្ដងចំពោះសំណើសុំ។ ការបដិសេធបែបនេះ បើកផ្លូវឱ្យប្ដឹងឧទ្ធរណ៍អនុលោមតាមវិធាន ៧៤(៣)(ឃ) នៃវិធានផ្ទៃក្នុង។ ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្ដឹងឧទ្ធរណ៍នេះអាចទទួលយកបាន។

១៧. នៅក្នុងកាលៈទេសៈទាំងនេះ អង្គបុរេជំនុំជម្រះមិនចាំបាច់លើកឡើងអំណះអំណាងផ្សេងទៀត ដែលសហមេធាវីការពារក្ដីបានលើកឡើងនោះទេ។

## ជំពូក ៣ - សេចក្ដីពិចារណា

### ក. សិទ្ធិរបស់ជនត្រូវចោទ ស្នើសុំឱ្យចាត់តាំងអ្នកជំនាញ ដើម្បីវាយតម្លៃសមត្ថភាពចូលរួមក្នុងកិច្ចស៊ើបសួរ

១៨. វិធាន៣២ នៃវិធានផ្ទៃក្នុងចែងថា៖

> "ក្នុងគោលបំណងដើម្បីបញ្ជាក់ថា ជនត្រូវចោទ ឬជនជាប់ចោទ មានសម្បទាខាងផ្លូវកាយ និងផ្លូវចិត្តអាចចូលរួមក្នុងការជម្រះក្ដី ឬក៏ដោយសារមូលហេតុផ្សេងទៀត ឬតាមសំណើរបស់ភាគីណាមួយ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអាចបង្គាប់ឲ្យជនត្រូវចោទ ឬជនជាប់ចោទទទួលការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រ វិកលចរិត ចិត្តសាស្ត្រ ដោយអ្នកជំនាញ។ មូលហេតុនៃការចេញសេចក្ដីបង្គាប់បែបនេះ និងរបាយការណ៍របស់អ្នកជំនាញ ត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង។"

១៩. អង្គបុរេជំនុំជម្រះយល់ឃើញថា វិសាលភាពនៃវិធាន៣២ នៃវិធានផ្ទៃក្នុង ដែលចែងថា អ្នកជំនាញអាចត្រូវបានគេចាត់តាំង "ដោយសារមូលហេតុផ្សេងទៀត" មានន័យទូលាយគ្រប់គ្រាន់ សមស្របទៅនឹងសំណើសុំរបស់សហសហមេធាវីការពារក្ដី។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

00233635

D54/IV/6



២០. អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញទៀតថា លិខិតបទដ្ឋានគតិយុត្តិរបស់អ.វ.ត.ក[១៥] វិធានផ្ទៃក្នុង និងច្បាប់កម្ពុជាមិនបានកំណត់ឱ្យបានច្បាស់លាស់អំពីអត្ថន័យ "សម្បទាចូលរួមក្នុងដំណើរការជំនុំជម្រះ"។ យើងមិនឃើញមានការបញ្ជាក់ថា នៅពេលណាដែលការវាយតម្លៃផ្នែកវិកលចរិតអាចត្រូវបានគេស្នើសុំ ឬក៏ថាតើសមត្ថភាពស្មារតីរបស់ជនត្រូវចោទអាចជាបញ្ហាយ៉ាងដូចម្ដេច ដែលគេអាចលើកឡើងនៅក្នុងដំណាក់កាលមុនអង្គសេចក្ដី។ ដូច្នេះ ដូចដែលបានចែងក្នុងមាត្រា១២ នៃកិច្ចព្រមព្រៀង អង្គបុរេជំនុំជម្រះ នឹងស្វែងរកបទដ្ឋានណែនាំលើបញ្ហានីតិវិធី ដែលត្រូវបានបង្កើតឡើងនៅកម្រិតអន្តរជាតិ។

២១. នៅក្នុងរឿងក្ដី*រដ្ឋអាជ្ញា តទល់នឹង Strugar* អង្គជំនុំជម្រះសាលាដំបូង នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) បានទទួលសំណើពីមេធាវីការពារក្ដីសុំឱ្យបញ្ឈប់ដំណើរការនីតិវិធី ដោយលើកមូលហេតុថា ជនជាប់ចោទមិនមានសម្បទាគ្រប់គ្រាន់ចូលរួមដំណើរការជំនុំជម្រះ[១៦]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា បទប្បញ្ញត្តិនៅក្នុងលក្ខន្តិកៈមិនមានចែងច្បាស់អំពីករណីនេះ ដែលអាចឱ្យយើងយកមកធ្វើជាសម្អាង។ ប៉ុន្តែ អង្គជំនុំជម្រះបានសង្កេតឃើញថា លក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ផ្ដល់ឱ្យជនជាប់ចោទនូវសិទ្ធិទទួលបានតាមនីតិវិធីយ៉ាងច្រើន។ ដូច្នេះ តុលាការនេះយល់ឃើញថា "ការទទួលបានសិទ្ធិទាំងនេះ អាស្រ័យលើករណីដែលថាជនជាប់ចោទមានសមត្ថភាពរាងកាយ និងស្មារតី ត្រឹមកម្រិតមួយ"[១៧]។ តុលាការនេះ

---

[១៥] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាស្ដីអំពីការកាត់សេចក្ដីក្រោមច្បាប់ព្រហ្មទណ្ឌកម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង")។ ច្បាប់ស្ដីពីការបង្កើតឱ្យមាន អ.វ.ត.ក ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ("ច្បាប់ អ.វ.ត.ក")។

[១៦] *រដ្ឋអាជ្ញា តទល់នឹង Strugar* សំណុំរឿងលេខ IT-01-42-T "សេចក្ដីសម្រេចចំពោះសំណើសុំមេធាវីការពារក្ដីសុំឱ្យបញ្ឈប់ដំណើរការនីតិវិធី" អង្គជំនុំជម្រះសាលាដំបូងទី II ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៤ ("សេចក្ដីសម្រេចលើរឿងក្ដី *Strugar*")។

[១៧] សេចក្ដីសម្រេចលើសំណុំរឿង *Strugar* កថាខណ្ឌទី ២១។ សូមអានផងដែរ៖ រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Stanisic* សំណុំរឿងលេខ IT-03-69 "សេចក្ដីសម្រេចលើសំណើសុំមេធាវីការពារក្ដីរបស់ Stanisic ស្ដីអំពីសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមក្នុងដំណើរការជំនុំជម្រះដោយមានឧបសម្ពន្ធសម្ងាត់" អង្គជំនុំជម្រះសាលាដំបូងទី II ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៦ ("សេចក្ដីសម្រេចលើសំណុំរឿង *Stanisic*") ទំព័រទី ២ និង៣។ រឿងក្ដី *អគ្គរដ្ឋអាជ្ញារងសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ តទល់នឹង Nahak* សំណុំរឿងលេខ 01A/2004 "ការយល់ឃើញ និងដីកាបង្គាប់ចំពោះសមត្ថភាពរបស់ជន



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

បានបញ្ជាក់ទៀតថា "លក្ខណៈនៃសិទ្ធិទាំងនេះបង្ហាញថា ការអនុវត្តន៍សិទ្ធិទាំងនេះឱ្យមានប្រសិទ្ធភាពអាចត្រូវបានប៉ះពាល់ ឬក៏អាចត្រូវរារាំង ប្រសិនបើសមត្ថភាពរាងកាយ និងស្មារតីរបស់ជនជាប់ចោទ ជាពិសេសសមត្ថភាពក្នុងការយល់ដឹង ឧទាហរណ៍ សមត្ថភាពដែលអាចយល់បាន ត្រូវបានប៉ះពាល់ដោយជម្ងឺផ្នែករាងកាយ ឬស្មារតី"[១៨]។ តុលាការបានសម្រេចថា "យើងចាំបាច់ទាញការសន្និដ្ឋានចេញពីលក្ខន្តិកៈតុលាការថា ប្រសិនបើមានហេតុផលគ្រប់គ្រាន់មែននោះ គឺតុលាការដែលជាអ្នកសម្រេចលើបញ្ហាទាំងឡាយ មិនថាជាបញ្ហាសម្បទារបស់ជនចាប់ចោទចូលរួមដំណើរក្នុងការជំនុំជម្រះ ឧទាហរណ៍ ជនជាប់ចោទចាំបាច់មានសមត្ថភាព ឬក៏ជាបញ្ហាថា ជនជាប់ចោទអាចអនុវត្តសិទ្ធិទាំងនេះ ដោយមានជំនួយពីមេធាវី"[១៩]។

២២. អង្គជំនុំជម្រះសាលាដំបូងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ក៏បានរកឃើញផងដែរថា នៅក្នុងរឿងក្តី *Strugar* សម្បទារបស់បុគ្គលក្នុងការចូលរួមក្នុងដំណើរការជំនុំជម្រះ គឺក្តោបបញ្ចូលទាំងសមត្ថភាពរបស់បុគ្គលនោះ "ក្នុងការសារភាពទោស យល់ដឹងពីលក្ខណៈនៃបទចោទ យល់ដឹងពីដំណាក់ការនីតិវិធី យល់ដឹងអំពីសេចក្តីពិស្តារនៃភស្តុតាង ពន្យល់ណែនាំប្រាប់មេធាវីការពារក្តី យល់ដឹងអំពីផលវិបាកនៃដំណើរការនីតិវិធី និងការផ្តល់សក្ខីកម្ម"[២០]។

២៣. ទាក់ទិនទៅនឹងអង្គហេតុដែលថា ជនជាប់ចោទត្រូវបានតំណាងដោយមេធាវី អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា៖

---

ចោទ Nahak ក្នុងការចូលរួមក្នុងដំណើរការជំនុំជម្រះ" គណៈកម្មការពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរក្នុងប្រទេសទីម័រខាងកើត (សាលាដំបូង Dili) ថ្ងៃទី១ ខែមីនា ឆ្នាំ២០០៥ ("សេចក្តីសម្រេចលើសំណុំរឿង *Nahak*") វាក្យខណ្ឌទី ៣២ ដល់ វាក្យខណ្ឌទី ៤៨។

[១៨] សេចក្តីសម្រេចលើសំណុំរឿង *Strugar* វាក្យខណ្ឌទី ២៣។

[១៩] សេចក្តីសម្រេចលើសំណុំរឿង *Strugar* វាក្យខណ្ឌទី ២៥។

[២០] សេចក្តីសម្រេចលើសំណុំរឿង *Strugar* វាក្យខណ្ឌទី ៣៦។ សូមអានផងដែរ៖ *រដ្ឋអាជ្ញា តទល់នឹង Kovacevic,* IT-01-42/2-1 "របាយការណ៍ជាសាធារណៈនៃសេចក្តីសម្រេចស្តីអំពីសម្បទាក្នុងការសារភាពទោស និង ដំណើរការជំនុំជម្រះ" អង្គជំនុំជម្រះសាលាដំបូង កាលពីថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៦ វាក្យខណ្ឌទី២៩។ សេចក្តីសម្រេចលើ សំណុំរឿង *Nahak* វាក្យខណ្ឌទី ៤១។ រឿងក្តី *S.C. តទល់នឹង ចក្រភពអង់គ្លេស* វាក្យខណ្ឌទី ២៩។



PRE-TRIAL CHAMBER * CHAMBRE PRELIMINAIRE * E.C.C.C * C.E.T.C

00233637

D54/V/6



"ការមានមេធាវី[...] គឺជាមធ្យោបាយមួយ ដែលអាចប៉ះប៉ូវគ្រប់គ្រាន់ ចំពោះវិការៈដែលពាក់ព័ន្ធ។ ប៉ុន្តែ ការប្រើប្រាស់មេធាវី តម្រូវឱ្យជនជាប់ចោទមានសមត្ថភាពអាចពន្យល់ណែនាំមេធាវីឱ្យបានច្បាស់លាស់ ដើម្បីឱ្យមេធាវីអនុវត្តតាមគោលបំណងរបស់កូនក្ដីគាត់"[២១]។

២៤. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ក្នុងសេចក្ដីសម្រេចក្នុងរឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Stanisic* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានអនុវត្តតាមសម្អាងហេតុនៅក្នុងសំណុំរឿង *Strugar* នៅពេលធ្វើសេចក្ដីសម្រេចលើសំណើសុំ នៅក្នុងដំណាក់កាលមុនអង្គសេចក្ដី ចំពោះបញ្ហាសម្បទាជនជាប់ចោទក្នុងការអនុវត្តន៍សិទ្ធិជាមូលដ្ឋាន ដើម្បីចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងការការពារខ្លួន[២២]។

២៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ចាប់តាំងពីពេលបើកកិច្ចស៊ើបសួរនៅ អ.វ.ត.ក ជនត្រូវចោទទទួលបានសិទ្ធិតាមនីតិវិធី ដូចដែលបានលើកឡើងនៅក្នុងរឿងក្ដី *Strugar*។ ក្នុងចំណោមសិទ្ធិទាំងនេះ រួមមានសិទ្ធិទទួលបានការជូនដំណឹងអំពីបទចោទដាក់បន្ទុកមកលើខ្លួន សិទ្ធិត្រៀមរៀបចំការពារខ្លួន និងសិទ្ធិការពារខ្លួន[២៣]។ បទប្បញ្ញត្តិជាច្រើននៅក្នុងវិធានផ្ទៃក្នុងក៏បានចែងបញ្ជាក់ផងដែរថា ជនត្រូវចោទត្រូវបានគេផ្ដល់ឱកាសឱ្យដើរតួនាទីសកម្មក្នុងដំណាក់ការស៊ើបអង្កេតនៅ អ.វ.ត.ក[២៤]។

២៦. ដោយសារតែការទទួលបានសិទ្ធិទាំងនេះ តម្រូវឱ្យជនត្រូវចោទមានសមត្ថភាពរាងកាយ និងស្មារតី អង្គបុរេជំនុំជម្រះពិចារណាឃើញថា បញ្ហាសមត្ថភាពរបស់ជនត្រូវចោទក្នុងការចូលរួម

---

[២១] សេចក្ដីសម្រេចលើសំណុំរឿង *Strugar* វាក្យខណ្ឌទី ២២។

[២២] សេចក្ដីសម្រេចលើសំណុំរឿង *Strugar*។

[២៣] មាត្រា៣៥ (ថ្មី) នៃច្បាប់ អ.វ.ត.ក។

[២៤] ជនត្រូវចោទ ដោយមានជំនួយពីមេធាវីដែលបំពេញតួនាទីស្របតាមការណែនាំពីកូនក្ដីរបស់ខ្លួន អាច ស្នើសុំបើកកិច្ចស៊ើបសួរ (វិធានផ្ទៃក្នុង ៥៥(១០) និង ៦៦) សំណើសុំចាត់តាំងអ្នកជំនាញ (វិធានផ្ទៃក្នុង ៣១(១០)) បណ្ដឹងជំទាស់ចំពោះចៅក្រម (វិធានផ្ទៃក្នុង ៣៤) ពិនិត្យមើលសំណុំរឿង (វិធានផ្ទៃក្នុង ៥៥(៦) និង ១១) ការបង្ហាញខ្លួននៅចំពោះមុខសហចៅក្រមស៊ើបអង្កេត (វិធានផ្ទៃក្នុង ៥៨) ដាក់បណ្ដឹងឧទ្ធរណ៍ជូនអង្គបុរេជំនុំជម្រះ ចំពោះសេចក្ដីសម្រេចមួយចំនួនដែលសម្រេចដោយសហចៅក្រមស៊ើបអង្កេត (វិធានផ្ទៃក្នុង ៧៣ និង ៧៤) បណ្ដឹងសុំមោឃភាពផ្នែកខ្លះនៃសំណុំរឿងនីតិវិធី (វិធានផ្ទៃក្នុង ៧៦) និងជាទូទៅ ចូលរួមក្នុងកិច្ចស៊ើបសួរដោយផ្ដល់នូវភស្តុតាង និងសាក្សី (វិធានផ្ទៃក្នុង ៥៨(៦))។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C.

ប្រកបដោយប្រសិទ្ធិភាពក្នុងដំណើរការនីតិវិធី បានកើតមានឡើងចាប់តាំងពីពេលដែលជនត្រូវចោទត្រូវ បានចោទប្រកាន់ពីបទឧក្រិដ្ឋនៅចំពោះមុខ អ.វ.ត.ក។ ដូចដែលសហមេធាវីការពារក្តីបានបញ្ជាក់ សមត្ថភាពរបស់ជនត្រូវចោទក្នុងការសហការជាមួយមេធាវីរបស់គាត់ មានការពាក់ព័ន្ធយ៉ាងខ្លាំង ជាពិសេសក្នុងអំឡុងពេលនៃដំណាក់ការស៊ើបអង្កេត។[២៥]

២៧. ដូច្នេះ អង្គបុរេជំនុំជម្រះបានយល់ឃើញថា ជាគោលការណ៍ ជនត្រូវចោទទទួលបានសិទ្ធិកោសល្យវិច័យដោយអ្នកជំនាញ ប្រសិនបើការស្នើសុំកោសល្យវិច័យនេះសមហេតុសមផល។ ការផ្តល់សិទ្ធិឱ្យគាត់បែបនេះ គឺដើម្បីឲ្យគាត់មានលទ្ធភាពអនុវត្តសិទ្ធិដែលទទួលតាមនីតិវិធីប្រកបដោយប្រសិទ្ធភាពក្នុងអំឡុងពេលស៊ើបអង្កេត និងដំណាក់កាលមុនអង្គសេចក្តី។ ក្នុងករណីនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា បញ្ហាសម្បទា ពិតជាកើតមាននៅក្នុងដំណាក់កាលនេះ ដែលវាផ្ទុយពីការអះអាងរបស់សហចៅក្រមស៊ើបអង្កេត។

## ខ. អង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍

២៨. សហមេធាវីការពារក្តីស្នើឡើងថា ជនត្រូវចោទគួរតែធ្វើកោសល្យវិច័យដោយ "អ្នកជំនាញផ្នែកវិកលចរិត ឬអ្នកចិត្តវិទ្យានៃមន្ទីរពេទ្យណាមួយ ឬពេទ្យសម្រាប់មនុស្សចាស់"[២៦] ដោយសារមូលដ្ឋាននៃអង្គហេតុដូចខាងក្រោម៖

- "[ជនត្រូវចោទ] មានអាយុ ៨២ ឆ្នាំ។ គាត់មានជំងឺបេះដូងច្រើនប្រភេទ ដែលពេលបច្ចុប្បន្ននេះ គាត់កំពុងទទួលការព្យាបាល និងការតាមដានជាប្រចាំ។"[២៧]
- ជនត្រូវចោទ បានត្អូញត្អែរម្តងហើយម្តងទៀតអំពីសម្បទាស្មារតីរបស់គាត់ ដោយប្រាប់អំពី "[ភាព]មិនប្រក្រតីនៃខួរក្បាលរបស់គាត់"[២៨] "[គាត់][មាន]អាការៈធ្ងន់ក្បាល និងមិនអាចស្តាប់លឺច្បាស់"[២៩] "ការគិតរបស់គាត់មិនច្បាស់ខ្លួនឯងសោះ"។[៣០]

---

[២៥] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ១៧។

[២៦] ពាក្យសុំ វាក្យខណ្ឌទី ២៧។

[២៧] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ៥។

[២៨] កំណត់ហេតុនៃការសួរយកចម្លើយជនត្រូវចោទ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៧ D23 ទំព័រទី ៣។

[២៩] កំណត់ហេតុនៃការសួរយកចម្លើយជនត្រូវចោទ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៧ D27 ទំព័រទី ៣។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE ១១

00233639

D54/V/6



- ជនត្រូវចោទមានសភាពអស់កម្លាំង និងវិលមុខ នៅពេលសវនាជាសាធារណៈរបស់អង្គបុរេជំនុំជម្រះ ដែលប្រកាសសាលដីកាលើការឃុំខ្លួនបណ្ដោះអាសន្ន ដោយសារគាត់គេងមិនលក់ស្កប់ស្កល់កាលពីយប់មិញ។[៣១]

២៩. សហមេធាវីការពារក្ដីគូសបញ្ជាក់ថា មេធាវីការពារក្ដី "នៅក្នុងដំណាក់កាលនេះ មិនសុំធ្វើការប្រកាសថា លោក **នួន ជា** មិនមានសម្បទាចូលរួមក្នុងការជំនុំជម្រះនោះទេ" ប៉ុន្តែស្នើសុំ "ឱ្យធ្វើ*កោសល្យវិច័យ*លើភាពខុសគ្នា ដែលសហចៅក្រមស៊ើបអង្កេតបានបង្គាប់ឡើង"[៣២]។ នៅក្នុងការយល់ឃើញរបស់សហមេធាវីការពារក្ដី "ឧបសគ្គជាបឋមនេះមិនមែនជាឧបសគ្គធ្ងន់ធ្ងរនោះទេ។"[៣៣]

៣០. សហព្រះរាជអាជ្ញា មិនជំទាស់នឹងការចាត់តាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រដែលមានគុណសម្បត្តិគ្រប់គ្រាន់ ដើម្បីវាយតម្លៃសម្បទារបស់លោក **នួន ជា** ក្នុងការចូលរួមក្នុងការជំនុំជម្រះនោះ ឡើយ ទោះបីជាសហព្រះរាជអាជ្ញាពិចារណាឃើញថា អង្គហេតុមិនបានបំពេញការសាកល្បង ដែលចែងនៅក្នុងយុត្តិសាស្ត្រអន្តរជាតិក៏ដោយ។

៣១. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ទាំងវិធានផ្ទៃក្នុង និងច្បាប់កម្ពុជាមិនបានចែងច្បាស់អំពីមូលដ្ឋានសម្រាប់ការដាក់សំណើសុំឱ្យមានការធ្វើកោសល្យវិច័យពីអ្នកជំនាញ។ ដូច្នេះ ជាថ្មីម្ដងទៀត អង្គបុរេជំនុំជម្រះនឹងស្វែងរកបទដ្ឋានណែនាំស្ដីពីនីតិវិធី ដែលបានបង្កើតឡើងនៅកំរិតអន្តរជាតិ។

៣២. ក្នុងសេចក្ដីសម្រេចលើរឿងក្ដី *Stanistic* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានយល់ឃើញថា យើងចាំបាច់ត្រូវមាន

---

[៣០] លិខិតរបស់លោក សុន អរុណ ផ្ញើរជូនការិយាល័យសហចៅក្រមស៊ើបអង្កេតស្ដីពីបណ្ដឹងលើបញ្ហាសុខភាព ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០០៨ D54/VI ទំព័រទី ២។

[៣១] សារណាបណ្ដឹងឧទ្ធរណ៍ វាក្យខណ្ឌទី ៥។

[៣២] សារណាបណ្ដឹងឧទ្ធរណ៍ វាក្យខណ្ឌទី ១៨។

[៣៣] សារណាបណ្ដឹងឧទ្ធរណ៍ វាក្យខណ្ឌទី ១៨។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C. ១២

00233640



““ហេតុផលគ្រប់គ្រាន់” ដើម្បីអាចធ្វើកោសល្យវិច័យលើសមត្ថភាពរបស់ជនជាប់ចោទក្នុងការចូលរួមដំណើរការជំនុំជម្រះ”[៣៤]។

៣៣. លក្ខខណ្ឌអប្បបរមាដែលជនត្រូវចោទត្រូវប្រកាសថា ខ្លួនមានសម្បទាក្នុងការចូលរួមក្នុងដំណើរការជំនុំជម្រះ ត្រូវបានចែងដោយអង្គជំនុំជម្រះសាលាដំបូងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ក្នុងសេចក្ដីសម្រេចលើរឿងក្ដី *Strugar* ដូចខាងក្រោម ៖

> “វានឹងមិនមានភាពសមស្រប មិនសមហេតុផល និងខុសពីទ្រឹស្ដីតែម្ដង ចំពោះការអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ក្នុងលក្ខខណ្ឌតម្រូវថា សម្បទានីមួយៗត្រូវតែបង្ហាញចេញក្នុងកម្រិតមួយខ្ពស់បំផុតដែលគួរឱ្យកត់សម្គាល់ ឬកម្រិតខ្ពស់បំផុតដែលជនជាប់ចោទណាម្នាក់មិនធ្លាប់មានចំពោះសម្បទាទាំងនោះ។ (...) អ្វីដែលជាលក្ខខណ្ឌតម្រូវនោះគឺជាបទដ្ឋានអប្បបរិមានៃសម្បទាទាំងអស់ ដែលកម្រិតអប្បបរិមានេះ មិនអាចឱ្យយកជនជាប់ចោទមកធ្វើការជំនុំជម្រះ ដោយសារ ភាពមិនត្រឹមត្រូវ ឬភាពអយុត្តិធម៌។ (...) កម្រិតអប្បបរិមាត្រូវបានបំពេញ នៅពេលជនជាប់ចោទម្នាក់មានសម្បទាទាំងនោះ ដែលត្រូវបានគេមើលឃើញជារួមថា មានលក្ខណៈត្រឹមត្រូវ និងសមហេតុផលដែលស្ថិតក្នុងកម្រិតមួយអាចឱ្យជនជាប់ចោទចូលរួមក្នុងកិច្ចដំណើរការនីតិវិធី (នៅក្នុងករណីខ្លះដោយមានជំនួយការពារក្ដី) និងអាចឱ្យជនជាប់ចោទអនុវត្តសិទ្ធិដែលមានគ្រប់គ្រាន់ ដូចជា សិទ្ធិក្នុងការការពារក្ដី។”[៣៥]

៣៤. គណៈកម្មការពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅទីម័រខាងកើត បានសម្រេចសេចក្ដីក្នុងរឿងក្ដី *Nahak* ថា “ដោយពិចារណាអំពីព័ត៌មានដែលបានទទួល យើងឃើញមានមូលដ្ឋាន គ្រប់គ្រាន់តម្រូវឱ្យមានការវិនិច្ឆ័យដោយឯករាជ្យលើចុងចោទទាក់ទិនទៅនឹងសមត្ថភាពស្មារតី ក្នុងការចូលរួមក្នុងដំណើរការជំនុំជម្រះ”[៣៦]។ តុលាការបានបញ្ជាក់បន្ថែមទៀតថា ដើម្បីបើកសវនាការលើបញ្ហាសមត្ថភាពនេះបាន “ដាច់ខាតត្រូវមានមន្ទិលសង្ស័យត្រឹមកម្រិតណាមួយ

---

[៣៤] សេចក្ដីសម្រេចលើសំណុំរឿង *Stanisic*។ សូមអានផងដែរ៖ សេចក្ដីសម្រេចលើសំណុំរឿង *Strugar* វាក្យខណ្ឌទី២៤ និងសេចក្ដីសម្រេចលើ សំណុំរឿង Nahak វាក្យខណ្ឌទី២៤ វាក្យខណ្ឌទី ៤៩ និងវាក្យខណ្ឌទី ៥០។

[៣៥] សេចក្ដីសម្រេចលើករណី *Strugar* វាក្យខណ្ឌទី ៣៧។ សេចក្ដីសម្រេចលើករណី *Kovacevic* វាក្យខណ្ឌទី ២៧។ គោលការណ៍នេះត្រូវបានគណៈវិនិច្ឆ័យពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅក្នុងប្រទេស East Timor យកមកអនុវត្តនៅក្នុងសេចក្ដីសម្រេចលើករណី *Nahak* វាក្យខណ្ឌទី ១២១។

[៣៦] សេចក្ដីសម្រេចលើសំណុំរឿង *Nahak* វាក្យខណ្ឌទី៧។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C. ១៣

ចំពោះសម្បទារបស់ចុងចោទក្នុងការចូលរួមក្នុងការជំនុំជម្រះ" ហើយ "ដាច់ខាតត្រូវមានកម្រិតព្រួយបារម្ភខ្លាំងក្លា ចំពោះសម្បទារបស់ចុងចោទ ដែលជាក្ដីព្រួយបារម្ភរបស់តុលាការ។"[៣៧]

៣៥. ដោយធ្វើការស្វែងរកបទដ្ឋានណែនាំនៅក្នុងយុត្តិសាស្ត្រនេះ អង្គបុរេជំនុំជម្រះនឹងពិនិត្យមើលបណ្ដឹងឧទ្ធរណ៍សារជាថ្មី ដោយសម្រេចថាតើបណ្ដឹងឧទ្ធរណ៍នេះ បានលើកឡើងមូលហេតុគ្រប់គ្រាន់ដែរឬទេ ទាក់ទងនឹងសមត្ថភាពរបស់ជនត្រូវចោទក្នុងការចូលរួមក្នុងដំណើរការនីតិវិធី ដោយមានជំនួយពីសហមេធាវីរបស់គាត់ ហើយថាតើសមត្ថភាពនេះអាចឱ្យគាត់អនុវត្តសិទ្ធិរបស់គាត់ប្រកបដោយប្រសិទ្ធភាពដែរឬទេ ក្នុងអំឡុងពេលស៊ើបអង្កេត។

៣៦. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានបង្គាប់ចាត់តាំងអ្នកជំនាញឯកទេសផ្នែកបេះដូងចំនួនបួនរូប នៅដំណាក់កាលខុសៗគ្នា ដើម្បីធ្វើកោសល្យវិច័យ ដោយសារសហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា "វាជាការចាំបាច់ដែលត្រូវឱ្យមានការធ្វើកោសល្យវិច័យដើម្បីកំណត់ពីរោគសាស្ត្រដែលលោក **នួន ជា** មាន និងដើម្បីវាយតម្លៃពីផលវិបាកបាកលើការស៊ើបអង្កេត ក្នុងពេលអនាគត"។ សហចៅក្រមស៊ើបអង្កេតបានចាត់តាំងពេទ្យជំនាញបេះដូង ឱ្យបំពេញបេសកកម្មដូចបង្ហាញខាងក្រោម:

> "ធ្វើការពិនិត្យសុខភាពជនជាប់ឃុំ **នួន ជា** និង បន្ទាប់ពីបានយល់ដឹងពីសំណុំឯកសារពិនិត្យសុខភាពរបស់ជននេះនៅមន្ទីរឃុំឃាំងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងនៅមន្ទីរពេទ្យកាល់ម៉ែត ហើយលោកទទួលបានព័ត៌មានចាំបាច់នានាដែលប្រមូលបាន យើងសូមឱ្យលោកឆ្លើយនឹងសំណួរដូចតទៅ៖
>
> ១. តាមការពិនិត្យ តើជននេះមានរោគសាស្ត្រអ្វីខ្លះជាពិសេសដែរឬទេ? ប្រសិនបើមាន សូមពិពណ៌នាពីរោគទាំងនេះ និងផ្ដល់យោបល់ថាតើវាពាក់ព័ន្ធនឹងជំងឺអ្វី <u>ដោយបញ្ជាក់ពីផលលំបាករបស់វាដែលអាចកើតមានចំពោះការចងចាំ និងសមត្ថភាពយល់ដឹងរបស់សាម៉ីខ្លួន។</u>
>
> ២. សូមផ្ដល់យោបល់ តើភាពមិនប្រក្រតីដែលរកឃើញនេះ ទាមទារចាំបាច់ឱ្យមានការព្យាបាល ឬការថែទាំពិសេស ឬក៏វាចចាំឱ្យមានការហាមឃាត់ប្រើថ្នាំណាមួយ។ <u>និយាយឱ្យចំ តើរោគសាស្ត្រទាំងនេះទាមទារឱ្យមានវិធានការពិសេសដែរឬទេ ទាក់ទងនឹងលក្ខខណ្ឌនៃការឃុំខ្លួនជននេះ</u>

---

[៣៧] សេចក្ដីសម្រេចលើករណី *Nahak* វាក្យខណ្ឌទី ៤៩ និងវាក្យខណ្ឌទី ៥០។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. * C.E.T.C.

00233642

D54/V/6

០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៧)

កំដូចជាការចូលរួមរបស់គេនៅក្នុងដំណើរការស៊ើបអង្កេត? ជាពិសេស តើត្រូវមានការប្រយ័ត្នដែរឬទេ នៅអំឡុងពេលនៃការសួរចម្លើយ ហើយប្រសិនបើមាន តើអ្វីខ្លះ?

៣. ប្រសិនជាអាច សូមសរសេរពីការស្មានទុកជាមុនអំពីការផ្លាស់ប្តូរស្ថានភាពជននេះថាតើអាចដុនដាបជាងមុន ឬអាចប្រសើរជាងមុន។

៤. ធ្វើការកត់សម្គាល់ផ្សេងៗទៀតទាំងអស់ដែលចាំបាច់ទាក់ទិននឹងស្ថានភាពសុខភាពរបស់ជនជាប់ឃុំនេះ។"[៣៨]

៣៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា វាក្យខណ្ឌចំនួនពីរនៅក្នុងសាលដីកាសម្ងាត់ ដែលធ្វើការពិភាក្សាលើស្ថានភាពសុខភាពរបស់ជនត្រូវចោទ ត្រូវបានលុបចោល ហើយត្រូវបានយកវាក្យខណ្ឌទី ៣៨ ខាងក្រោមនេះ មកជំនួសវិញ។

៣៨. នៅក្នុងខែតុលា ឆ្នាំ២០០៧ អ្នកឯកទេសផ្នែកបេះដូងចំនួនបីរូប បានធ្វើការពិនិត្យជនត្រូវចោទ ហើយបានធ្វើការសន្និដ្ឋានថា ជនត្រូវចោទមានជំងឺមួយចំនួន។

៣៩. ទោះបី ដូចដែលសហមេធាវីការពារក្តីបានលើកឡើង អ្នកជំនាញទាំងនេះ មិនមែនជាអ្នកឯកទេសផ្នែកសសៃប្រសាទ ឬចិត្តសាស្ត្រក៏ដោយ របាយការណ៍របស់ពួកគេទាំងអស់បាននាំដល់ការសន្និដ្ឋានថា សម្បទារបស់ជនត្រូវចោទ មិនមានអ្វីប៉ះពាល់ខ្លាំងក្លា ដោយសារជំងឺសសៃខួរក្បាលរបស់ជនត្រូវចោទឡើយ។ អ្នកឯកទេសទាំងនោះក៏បានសន្និដ្ឋានថា ដំណើរការខួរក្បាលរបស់ជនត្រូវចោទមានភាពប្រក្រតី ចំពោះបុគ្គលដែលស្ថិតក្នុងវ័យនេះ។ ការអះអាងរបស់សហមេធាវីការពារក្តីថា "មានភាពខុសគ្នាខ្លាំងលើបញ្ហាដំណើរការខួរក្បាលរបស់លោក នួន ជា"[៣៩] ហាក់ដូចជាគ្មានមូលដ្ឋានច្បាស់លាស់។

---

[៣៨] ដីកាចាត់តាំងអ្នកជំនាញ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៧ D24 ទំព័រទី ២។ ដីកាចាត់តាំងអ្នកជំនាញបន្ថែមចំនួនពីរទៀត ដើម្បីបំពេញបេសកកម្មដដែល។ សូមអាន: ដីកាចាត់តាំងអ្នកជំនាញ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ D24/VI និងដីកាចាត់តាំងអ្នកជំនាញ ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៨ D24/VIII (គូសបញ្ជាក់បន្ថែម)។

[៣៩] ពាក្យសុំចាត់តាំងអ្នកជំនាញ វាក្យខណ្ឌទី ២៣។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

៤0. នៅក្នុងសេចក្ដីសម្រេច *Strugar* ក្រុមប្រឹក្សាជំនុំជម្រះនៃអង្គជំនុំជម្រះសាលាដំបូងរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានយកសេចក្ដីសង្កេតរបស់ខ្លួនលើអាកប្បកិរិយារបស់ជនត្រូវចោទនៅក្នុងសវនាការ មកធ្វើការពិចារណា ហើយបានឈានដល់ការសន្និដ្ឋានមួយលើសម្បទាចូលរួមក្នុងការជំនុំជម្រះរបស់ជនចោទ:

> "ពេលឆ្លើយម្ដងៗ ជនជាប់ចោទហាក់ដូចជាបានផ្ដល់ចម្លើយសំខាន់ៗ ក្បោះក្បាយ ពេញលេញ ហើយថែមទាំងមានការរៀបឃ្លោងឃ្លាបានយ៉ាងត្រឹមត្រូវ។(...) យើងបានកត់ត្រាបញ្ហាទាំងនេះ ដោយសង្កេតឃើញថា អាកប្បកិរិយារបស់ជនត្រូវចោទ ក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធី មិនបានផ្ដល់ហេតុផលណាមួយធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងស្ទាក់ស្ទើរក្នុងការទទួលយកកោសល្យវិច័យរបស់អ្នកជំនាញខាងរដ្ឋអាជ្ញានោះឡើយអំពីសម្បទាចូលរួមក្នុងការជំនុំជម្រះរបស់ជនជាប់ចោទ។"[៤0]

៤១. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ជនត្រូវចោទបានផ្ដល់ចម្លើយសំខាន់ៗក្បោះក្បាយ ពេញលេញ ហើយថែមទាំងមានការរៀបឃ្លោងឃ្លាបានយ៉ាងត្រឹមត្រូវ ក្នុងអំឡុងពេលសវនាការនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត និងនៅចំពោះមុខអង្គបុរេជំនុំជម្រះ។[៤១] អាកប្បកិរិយារបស់ជនត្រូវចោទនៅក្នុងពេលសវនាការ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ មិនបានផ្ដល់ជាហេតុផលណាមួយ ដែលបង្កើតជាបញ្ហាចោទចំពោះកោសល្យវិច័យរបស់អ្នកឯកទេសផ្នែកបេះដូងឡើយ។

៤២. អង្គបុរេជំនុំជម្រះយល់ឃើញថា ការតវ៉ាជាអត្តនោម័តរបស់ជនត្រូវចោទអំពីសមត្ថភាពផ្នែកស្មារតីរបស់គាត់ មិនបានបន្ថយតម្លៃនៃការសន្និដ្ឋាននេះឡើយ ឬក៏ការតវ៉ានេះ មិនផ្ដល់យុត្តិកម្មចាំបាច់ចាត់តាំងអ្នកជំនាញបន្ថែមឡើយ។ កោសល្យវិច័យរបស់អ្នកឯកទេសផ្នែកបេះដូងចំនួនបួនរូប ហាក់ដូចជាមានភាពស្របគ្នាជាមួយនឹងអាកប្បកិរិយារបស់ជនត្រូវចោទ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះសាលាដំបូង។

---

[៤0] សេចក្ដីសម្រេចលើករណី *Strugar* វាក្យខណ្ឌទី ៥១។

[៤១] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២00៧ D20។ កំណត់ហេតុនៃសវនាការសួរតទល់គ្នា ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២00៧ C8។ កំណត់ហេតុនៃសវនាការ ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២00៨ (សវនាការសាធារណៈ) C11/61 ទំព័រទី ៣ និងទំព័រទី ៤។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

00233644

D54/V/16

០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៧)

៤៣. ដោយសារមូលហេតុទាំងនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើសុំចាត់តាំងអ្នកជំនាញដើម្បីធ្វើការវាយតម្លៃសម្បទារបស់ជនត្រូវចោទក្នុងការចូលរួមក្នុងការជំនុំជម្រះ និងសមត្ថភាពរបស់គាត់ក្នុងការចូលរួមដោយប្រសិទ្ធិភាពនៅក្នុងការការពារខ្លួន មិនមានមូលហេតុត្រឹមត្រូវឡើយ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន:**

១) បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបានតាមទម្រង់។

២) បដិសេធចោលសំណើសុំចាត់តាំងអ្នកជំនាញ។

៣) បដិសេធចោលបណ្តឹងឧទ្ធរណ៍។

ភ្នំពេញ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៨

**អង្គបុរេជំនុំជម្រះ**

Rowan DOWNING    នីយ ថុល    Katinka LAHUIS    ហួត វុទ្ធី    ប្រាក់ គឹមសាន